**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

CAMBODIA
Kingdom of Wonder
feel the warmth

**ក្រសួងទេសចរណ៍**

**លេខ** ០៣២ ប្រក

ថ្ងៃ ព្រហស្បតិ៍ ១៤កើត ខែ បុស្ស ឆ្នាំ ខាល ចត្វាស័ក ព.ស២៥៦៦

រាជធានីភ្នំពេញ, ថ្ងៃទី ០៥ ខែ មករា ឆ្នាំ២០២៣

# ប្រកាស
# ស្តីពី
# ការដាក់ឱ្យអនុវត្តគោលការណ៍ណែនាំស្តីពី ការទទួលស្គាល់គុណភាពបណ្តុះបណ្តាល ការវាយតម្លៃ និងសមត្ថភាពអ្នកជំនាញក្នុងវិស័យទេសចរណ៍

## រដ្ឋមន្ត្រីក្រសួងទេសចរណ៍

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៥ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ស្តីពីការបង្កើតក្រសួងទេសចរណ៍
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៩/០០៧ ចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០០៩ ប្រកាសឱ្យប្រើច្បាប់ស្តីពីទេសចរណ៍
- បានឃើញអនុក្រឹត្យលេខ ២៥៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០១៦ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងទេសចរណ៍
- យោងតាមតម្រូវការចាំបាច់នៃការងារ

## សម្រេច

**ប្រការ១ ._**

ត្រូវបានដាក់ឱ្យអនុវត្តគោលការណ៍ណែនាំស្តីពីការទទួលស្គាល់គុណភាពបណ្តុះបណ្តាល ការវាយតម្លៃ និងសមត្ថភាពអ្នកជំនាញក្នុងវិស័យទេសចរណ៍ ដើម្បីជាអភិក្រមណែនាំរួមសម្រាប់ធ្វើការវាយតម្លៃ និងបញ្ជាក់គុណភាពបណ្តុះបណ្តាល និងវាយតម្លៃសមត្ថភាពលើជំនាញទេសចរណ៍ ព្រមទាំងទទួលស្គាល់សមត្ថភាពជំនាញ និងគុណវុឌ្ឍិរបស់អ្នកបម្រើការងារក្នុងវិស័យទេសចរណ៍ បដិសណ្ឋារកិច្ច និងការធ្វើដំណើរផងដែរ ដូចមានចែងក្នុងឧបសម្ព័ន្ធនៃប្រកាសនេះ។

ដីឡូត៍លេខ៣A ផ្លូវលេខ១៦៩ សង្កាត់វាលវង់ ខណ្ឌ៧មករា រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទ: +៨៥៥ ២៣ ៨៨៤ ៩៧២ ទូរសារ: +៨៥៥ ២៣ ៨៨៤ ៩៧៤ E-mail: admin@mot.gov.kh Website: www.tourismcambodia.org

**ប្រការ២**._

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយទៅនឹងប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍។

**ប្រការ៣**._

នាយកខុទ្ទកាល័យ អគ្គនាយកនៃគ្រប់អគ្គនាយកដ្ឋាន នាយិកាវិទ្យាស្ថានជាតិទេសចរណ៍ អគ្គាធិការ ប្រធាននាយកដ្ឋានបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈទេសចរណ៍ គ្រប់ប្រធានអង្គភាពក្រោមឱវាទក្រសួងទេសចរណ៍ ប្រធានមន្ទីរទេសចរណ៍រាជធានី ខេត្ត គ្រឹះស្ថានអប់រំ និងបណ្តុះបណ្តាលជំនាញទេសចរណ៍ និងបដិសណ្ឋារកិច្ច សាលាបណ្តុះបណ្តាលជំនាញទេសចរណ៍ មជ្ឈមណ្ឌលបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈទេសចរណ៍ វិទ្យាស្ថានបណ្តុះបណ្តាលជំនាញទេសចរណ៍ ដៃគូអភិវឌ្ឍន៍ ក្រុមហ៊ុន ស្ថាប័នទេសចរណ៍ អ្នកផ្តល់សេវាបណ្តុះបណ្តាលជំនាញទេសចរណ៍ មជ្ឈមណ្ឌលវាយតម្លៃសមត្ថភាព មូលដ្ឋានអាជីវកម្មទេសចរណ៍ ប្រតិបត្តិករទេសចរណ៍ អ្នកជំនាញទេសចរណ៍ សមាគមឧស្សាហកម្មទេសចរណ៍ និងភាគីពាក់ព័ន្ធ ត្រូវទទួលអនុវត្តប្រកាសនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

**រដ្ឋមន្ត្រី**

**ថោង ខុន**

<u>កន្លែងទទួល៖</u>

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យ ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រីប្រចាំការ
- រដ្ឋបាលសាលារាជធានី ខេត្ត
- មន្ទីរទេសចរណ៍រាជធានី ខេត្ត
- គ្រឹះស្ថានអប់រំ និងបណ្តុះបណ្តាលជំនាញទេសចរណ៍ និងបដិសណ្ឋារកិច្ច
- សាលាបណ្តុះបណ្តាលជំនាញទេសចរណ៍ និងបដិសណ្ឋារកិច្ច
- មជ្ឈមណ្ឌលវាយតម្លៃសមត្ថភាព
- សមាគមឧស្សាហកម្មទេសចរណ៍
- ដូចប្រការ៣
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ